# សាមគ្គីធម៌
# សាមគ្គីភេទ
# និង
# សាមគ្គីភេទកៈ

រៀបរៀងដោយ
សម្ដេចព្រះពោធិវង្ស (ហ.ត. វជិរប្បញ្ញោ)
ពិនិត្យផ្ទៀងផ្ទាត់ដោយ
សម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ
(ជ.ណ. ជោតញ្ញាណោ)

ផ្ទះលេខ១៣៦អឹ០ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស. ២៥១២ គ.ស. ១៩៦៨

ផ្សាយចេញពី

www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# អារម្ភបទ

សៀវភៅឈ្មោះ **"សាមគ្គីធម៌ សាមគ្គីភេទ និង សាមគ្គីភេទកៈ"** នេះ ខ្ញុំបានរៀបរៀងឡើងពីក្នុង ព.ស. ២៥០៧ គ.ស. ១៩៦៤ ម៉្លេះ ដោយសម្ដេចព្រះសង្ឃរាជជួនណាត់ទី ១ ទ្រង់បានជួយពិនិត្យផ្ទៀងផ្ទាត់ផង ៗ សៀវភៅនេះខ្ញុំបានប្រគល់ទៅឲ្យរោងពុម្ព ពុទ្ធិរស្មី លេខ ៦៦ វិថីព្រះបាទសីហនុ ភ្នំពេញ បោះពុម្ពបីពាន់ក្បាល ដើម្បីចែកជាធម្មទានក្នុងឱកាសពិធីបុណ្យអនុ-សំវច្ឆរមហាសន្និបាតទី ២១ នៃមន្ត្រីសង្ឃក្នុង គ.ស. ១៩៦៤ ម្ដង រួចហើយ ៗ ឥឡូវក្នុងឆ្នាំ ១៩៦៨ នេះ លោក ណាង-ហ៊ាប អាង នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ ដែលត្រូវក្រសួងអប់រំជាតិប្រគល់ឲ្យទៅគាល់សម្ដេចព្រះសង្ឃរាជជាម្ចាស់ រៀបចំធ្វើកម្មវិធីសិក្សាផ្នែកពុទ្ធសាសនាក្នុងមធ្យមសិក្សា ក៏បានយល់ឃើញថា សៀវភៅ **"សាមគ្គីធម៌ សាមគ្គីភេទ និង សាមគ្គីភេទកៈ"** របស់ខ្ញុំ មានអត្ថន័យសមល្មមនឹងបញ្ចូលជាពពួកសៀវភៅនានាផ្នែកធម៌សម្រាប់បង្រៀនសិស្សានុសិស្ស ឲ្យស្គាល់នូវតម្លៃនៃសាមគ្គីនេះ ៗ លោក ណាង-ហ៊ាប អាង ក៏បានមកសុំយកតម្រានេះអំពីខ្ញុំ ដើម្បីផ្សាយឲ្យបានទូលំទូលាយដល់សិក្ខាកាម

កុលបុត្រ កុលធីតា ទាំងឡាយ ៗ អាត្មាមានសេចក្ដីពេញចិត្តចំពោះគំនិតផ្ដួចផ្ដើមរៀបចំកម្មវិធីផ្សព្វពុទ្ធសាសនាដែលក្រសួងអប់រំជាតិបានធ្វើឡើងនេះ ហើយបានសំរេច ប្រកាសសិទ្ធិនៃការផ្សាយសៀវភៅអាត្មានេះទៅ វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ដែលជាអង្គការរក្សាវប្បធម៌ អារ្យធម៌ជាតិ ដើម្បីទុកជាសម្បត្តិរដ្ឋ ក្នុងការបោះពុម្ពផ្សាយជាប្រយោជន៍ទូទៅ ។

នៅទីអវសាននេះ អាត្មាសូមប្រមូលនូវផលានិសង្ស ដែលកើតឡើងអំពីការផ្សាយក្បួនខ្នាតតម្រាច្បាប់ ខាងពុទ្ធសាសនានេះ ដើម្បីប្រសិទ្ធិថ្វាយ **សម្ដេចព្រះមហាក្សត្រិយានី** ជាអម្ចាស់ជីវិត **សម្ដេចព្រះប្រមុខរដ្ឋ** ព្រះបិតាជាតិ សូមព្រះអង្គបានប្រកបដោយព្រះជន្មាយុយឺនយូរ និង សុខសួស្ដី ក្នុងព្រះរាជសម្បត្តិគង់អង្វែងទៅ ហើយសូមពុទ្ធបរិស័ទ ក្នុងកម្ពុជរដ្ឋបានជួបប្រទះតែនូវសាមគ្គីភាពរុងរឿងមូលត្រកូលគ្នា ដើម្បីសេចក្ដីសុខ ចំរើនក្រោមម្លប់ព្រះពុទ្ធសាសនា ជាអង្វែងតទៅ ។

ភ្នំពេញ ថ្ងៃទី ១០ ឧសភា ២៥១២/១៩៦៨

សម្ដេចព្រះពោធិវង្ស

ហ.ត. ជិរប្បញ្ញោ

# សាមគ្គីធម៌

## នមោ រតនត្តយស្ស

សូមនមស្ការដោយគោរព ចំពោះព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។

លំដាប់អំពីនេះ ខ្ញុំករុណា អាត្មា សូមសំដែងអំពីសាមគ្គីធម៌ ជូនអស់លោក-អ្នកទាំងឡាយ ជាសេចក្ដីសង្ខេប ឲ្យសមដល់កាលវេលា ។ មុនដំបូង សូមលើកយកពាក្យថា "សាមគ្គី" មកចែកចេញជា ៥ យ៉ាងគឺ :

១– សាមគ្គី ការព្រមព្រៀងគ្នា;

២– សាមគ្គីធម៌ ច្បាប់សម្រាប់ប្រតិបត្តិ ឲ្យបានការព្រមព្រៀងគ្នា;

៣– សាមគ្គីភាព បែបបទ ឬរបៀបការព្រមព្រៀងគ្នា;

៤– សាមគ្គីរស រសជាតិរបស់ការព្រមព្រៀងគ្នា;

៥– សាយគ្គីរសានិសង្ស អានិសង្សនៃសាមគ្គីរស គឺផលដែលកើតអំពីការព្រមព្រៀងគ្នា, ជារសឆ្ងាញ់ក្រៃលែង ។

ទាំង ៤ នេះ មានសាមគ្គីជាមូលដ្ឋាន; គួរជ្រាបថា សាមគ្គី គឺការព្រមព្រៀងគ្នា ត្រូវមានសាមគ្គីធម៌ គឺច្បាប់សម្រាប់ប្រតិបត្តិ ឲ្យកើតបានសាមគ្គីភាព គឺបែបបទ ឬរបៀបនៃការព្រមព្រៀងគ្នា, សាមគ្គីភាពបង្កើតឲ្យមានសាមគ្គីរស គឺរសជាតិនៃការព្រមព្រៀងគ្នា ដែលនាំឲ្យពេញចិត្តស្រឡាញ់រាប់អានគ្នា, សាមគ្គីរសនេះ បង្កើតទៅជាសាមគ្គីសានិសង្ស ដែលជាផលសម្រេចតាមគោលបំណង ។ ព្រោះហេតុនោះសាធុជនគួរជ្រាបលក្ខណៈធម៌ទាំង ៤ នេះឲ្យជាក់ច្បាស់ គឺគួរជ្រាបថា សាមគ្គីសានិសង្សកើតមាន ព្រោះអាស្រ័យសាមគ្គីរស ។ កើតមាន ព្រោះអាស្រ័យសាមគ្គីភាព ។ កើតមាន ព្រោះអាស្រ័យសាមគ្គីធម៌ ដែលជាច្បាប់ប្រាប់របៀបបែបបទ នៃសាមគ្គី ។ នេះ ជាមូលដ្ឋានដើម ។

ឥឡូវនេះ ខ្ញុំករុណា អាត្មា នឹងសំដែងអំពីសាមគ្គីធម៌តទៅ, សូមនាំយកពុទ្ធភាសិតមកតម្កល់ទុកជាគោលថា :

សុខា សង្ឃស្ស សាមគ្គី

សមគ្គានំ តបោ សុខោ

"ការព្រមព្រៀងគ្នា នៃពួកក្រុម នាំឲ្យមានសុខស្រួល, សេចក្ដីព្យាយាម របស់អ្នកដែលមានការព្រមព្រៀងគ្នា នាំឲ្យបានសុខស្រួល", នេះ ជាឱវាទនៃព្រះសក្យមុនីគោតមបរមគ្រូរបស់យើង ។

## អធិប្បាយសង្ខេប

មនុស្សដែលមានចំនួនតាំងពីបួនប្រាំនាក់ឡើងទៅ រហូតរាប់រយរាប់ពាន់នាក់ ហៅថាពួកឬក្រុម ។ នេះ បើហៅតាមភាសាបាលីថា "សង្ឃ" ទោះបព្វជិតក្ដី គ្រហស្ថក្ដី ដែលមានចំនួនច្រើនហៅថា "សង្ឃ" ប្រែថា ពួក ឬក្រុម[1] ។ ក្នុងពួកក្រុមនីមួយៗ បើមានសាមគ្គី គឺការព្រមព្រៀងគ្នា ទើបបានសេចក្ដីសុខ ។ ឯសេចក្ដីសុខនោះ គឺស្រួល ឥតលំបាកចិត្ត ឥតទាស់ទែងគ្នា ឥតមានហេតុដែលនាំឲ្យស្អុះស្អាប់ក្នុងចិត្ត ។

ពួកក្រុមដែលមានការព្រមព្រៀងគ្នា ត្រូវការព្យាយាមបំពេញករណីយកិច្ចណាមួយ, សេចក្ដីព្យាយាមនោះ នឹងនាំឲ្យបានសុខ

---

១– សង្ឃៈ ស័ព្ទនេះ ប្រែថា ពួក,ក្រុម,ហ្វូង,បន ដូចជាភិក្ខុសង្ឃ ពួកភិក្ខុឬក្រុមភិក្ខុ; មិគសង្ឃ ពួកម្រឹគ ឬ ហ្វូងម្រឹគ; សកុណសង្ឃ ហ្វូងសត្វស្លាបជាដើម ។

ស្រួលទៀត គឺថាមិនបានសម្រេចតាមបំណង ឥតមានឧបសគ្គណា មួយមកស្កាត់ដំណើរបានឡើយ ព្រោះសាមគ្គីជាគ្រឿងឧបករណ៍ មួយដ៏ធំក្រៃលែង និងជាកម្លាំងមួយដ៏ខ្លាំងក្លាបំផុត ឬជាអាវុធមួយ ដ៏សក្តិសិទ្ធិបំផុត ។

សេចក្តីដែលពោលខាងលើនេះ ឃើញថា ការព្រមព្រៀង គ្នាជាបំណុចសំខាន់ក្នុងពួកក្រុមនីមួយ ៗ, ចុះការព្រមព្រៀងគ្នានោះ តើដូចម្តេច ? ការព្រមព្រៀងគ្នានោះ មាន៣ យ៉ាងគឺ :

១– ការព្រមព្រៀងគ្នាដោយកាយ ហៅថា "កាយសាមគ្គី",

២– ការព្រមព្រៀងគ្នាដោយវាចា ហៅថា "វចីសាមគ្គី",

៣– ការព្រមព្រៀងគ្នាដោយចិត្ត ហៅថា "មនោសាមគ្គី ឬ ចិត្តសាមគ្គី" ។

ការព្រមព្រៀងគ្នាដោយកាយ បានសេចក្តីថា ក្នុងពួកឬក្រុម នីមួយ ៗ ដែលជាសង្គមតូច ឬ ធំ កាលបើមានកិច្ចការអ្វីនីមួយ ដែលត្រូវធ្វើរួមគ្នា, ឥតមានអ្នកណាមួយហ៊ានសម្ងំលាក់ខ្លួនឡើយ គឺទៅប្រជុំរួមជាមួយគ្នា ជួយបំពេញកិច្ចការនោះ តាមកាលវេលា

ដែលបានកំណត់ទុក ទៀតសោតតែមានធុរៈផ្ទាល់ខ្លួន ជាធុរៈចាំបាច់ ហើយបានឲ្យដំណឹងជាមុន ។

ការព្រមព្រៀងគ្នាដោយវាចា បានសេចក្ដីថា ក្នុងឱកាស ដែលពួកក្រុមមានការប្រជុំ បញ្ចេញយោបល់រៀងខ្លួន ចំពោះកិច្ចការណាមួយដែលត្រូវបង្កើត ត្រូវធ្វើ, ប្រជុំជនក្នុងពួកក្រុមនោះ ចេះស្ដាប់គ្នាទៅវិញទៅមក បើឃើញថាអ្នកណាមានវាចាសមតាម ហេតុផលហើយ ក៏អនុលោមតាមភ្លាម មិនមានគំនិតគិតប្រឆាំង ហើយចេះតែស្រែកតក់ដោយមិនសមតាមហេតុផលឡើយ ។ បើ អ្នកណាម្នាក់ ស្ដាប់ទីប្រជុំដែលថ្លែងសេចក្ដីនោះ មិនពេញចិត្តខ្លួន ក៏ស្នើឱកាសថ្លែងឲ្យទីប្រជុំស្ដាប់ នូវយោបល់របស់ខ្លួន ទោះបីគេ ទទួលយក ឬមិនទទួលយក ក៏មិនអាក់អន់ស្រពន់ចិត្ត ។ មនុស្ស ភាគតិចក្នុងទីប្រជុំ ត្រូវអនុលោមស្របតាមមនុស្សភាគច្រើន ជា ដរាប ។

ការព្រមព្រៀងគ្នាដោយចិត្ត បានសេចក្ដីថា មានចិត្តស្មើគ្នា មានអធ្យាស្រ័យត្រូវគ្នា មិនធ្វើចិត្តឲ្យបែកកន្លែកចេញពីគ្នា មិនតាំងចិត្តដណ្ដើមប្រជែងយកឈ្នះគ្នា គឺធ្វើចិត្តឲ្យស្របរួមជាមួយគ្នា ។

ការធ្វើចិត្តឲ្យមួយ ជាការកម្រណាស់ ព្រោះតាមគម្ពីរក្នុងព្រះពុទ្ធ-សាសនាថា មនុស្សក្នុងលោកសន្និវាសនេះ នានត្តកាយា នានត្តសញ្ញី គឺមានកាយក៏ផ្សេងគ្នា ចិត្តក៏ផ្សេងគ្នាដែរ, តាំងកាយតាំងចិត្តមិនដូចគ្នាទេ ។ នេះ ជាសេចក្ដីពិតមែន ព្រោះរូបកាយនៃមនុស្សរាប់សែនរាប់លាននាក់ សុទ្ធតែផ្សេងពីគ្នា បើមិនផ្សេងច្រើនក៏គង់បន្តិចបន្តួច សូម្បីកូនភ្លោះក៏គង់ផ្សេងគ្នាខ្លះដែរ ល្មមឲ្យបំណាំបានឥតមានច្រឡំគ្នាឡើយ ។ រូបកាយផ្សេងពីគ្នាយ៉ាងណា ចិត្តក៏ផ្សេងគ្នាយ៉ាងនោះដែរ ។ អ្នកមានគំនិតប្រាជ្ញាដែលប្រាថ្នាចង់បានសេចក្ដីសុខរាល់ខ្លួននិងអ្នកដទៃ ក្នុងពួកក្រុមឬសង្គមនីមួយ ៗ នោះ គេតែងប្រដៅចិត្តពត់ចិត្តទប់ចិត្តរក្សាចិត្ត សម្របសម្រួលចិត្តរបស់ខ្លួនឲ្យស្របរួមជាមួយគ្នា មិនដណ្ដើមប្រជែងយកឈ្នះគ្នា បោះបង់អស្មិមានះចេញ ដើម្បីយកឱកាសឲ្យមានសាមគ្គី គឺការព្រមព្រៀងគ្នាតាមផ្លូវចិត្តកើតឡើង ក្នុងពួកក្រុមរបស់ខ្លួន វៀរលែងតែមនុស្សខ្លះក្នុងពួកក្រុមជាមួយ ដែលជាមនុស្សទុជ៌ន មានគំនិតអាក្រក់ មានសេចក្ដីយល់ខុសយ៉ាងច្បាស់លាស់, មនុស្សបែបនេះ ។ មិនត្រូវសម្រួលចិត្តអនុលោមបានឡើយ ត្រូវតែរួមគ្នា

បដិសេធមនុស្សដែលមានគំនិតអាក្រក់នោះចេញ កុំឲ្យនៅរួមក្នុងពួក ឬ សង្គមជាមួយឡើយ ។

ពួកក្រុម ឬ សង្គមណាមួយ ដែលមានការព្រមព្រៀងគ្នាហើយ កាលបើត្រូវការនឹងបំពេញមុខការណាមួយ ដែលមានប្រយោជន៍ជាសាធារណៈ សូម្បីការនោះធំហើយកម្រផងយ៉ាងណាក្តី, បើពួកក្រុម ឬ សង្គមនោះមិនបោះបង់សេចក្តីព្យាយាមចោលទេ កិច្ចការទាំងនោះ គង់នឹងបានសម្រេចតាមបំណង ដោយអាស្រ័យសាមគ្គីយ៉ាងមាំមួន ។

ម្យ៉ាងទៀត, សាមគ្គីនេះ ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ត្រាស់សរសើរថា ជាធម៌នាំឲ្យកើតសេចក្តីចម្រើន មិនមែននាំឲ្យកើតសេចក្តីវិនាសឡើយ ដូចពុទ្ធភាសិតក្នុងអបរិហានិយធម្មសូត្រ មានដូច្នេះជាដើមថា ៖

យាវកីវញ្ច ភិក្ខវេ ភិក្ខូ សមគ្គា
សន្និបតិស្សន្តិ សមគ្គា វុដ្ឋហិស្សន្តិ
សមគ្គា សង្ឃករណីយានិ ករិស្សន្តិ
វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា

ទោ បរិហានិ "ម្នាលភិក្ខុទាំងឡាយ, ពួកភិក្ខុ (ដែលមានចំនួនច្រើនរូប) ដែលត្រូវប្រជុំ ក៏ព្រមព្រៀងគ្នាប្រជុំ, ពេលដែលក្រោកចាកទីប្រជុំ ក៏ព្រមព្រៀងគ្នាក្រោក, ពេលដែលត្រូវធ្វើកិច្ចការរបស់សង្ឃ ក៏ព្រមគ្នាធ្វើកិច្ចការរបស់សង្ឃ, (កាលបើមានការព្រមព្រៀងគ្នាដូច្នេះ) អស់កាលត្រឹមណា, សេចក្តីចម្រើននឹងកើតមានប្រាកដដល់ភិក្ខុទាំងឡាយ មិនមែននាំឲ្យកើតសេចក្តីវិនាសឡើយ អស់កាលត្រឹមនោះ" ។

ពុទ្ធភាសិតមានប៉ុណ្ណេះជាដើម ជាព្រះបរមពុទ្ធោវាទដ៏ឧត្តមសម្រាប់ពួកបព្វជិតនិងគ្រហស្ថជាពុទ្ធបរិស័ទ ដែលមានបំណងចង់បានសេចក្តីចម្រើន, ចង់ចៀសវាងឲ្យផុតពីសេចក្តីវិនាស, គួរពិចារណាឲ្យយល់សេចក្តីក្នុងពុទ្ធភាសិតនេះ ឲ្យបានច្បាស់លាស់ ហើយគួរប្រតិបត្តិធ្វើតាម ។

## សេចក្តីអធិប្បាយ

ពុទ្ធភាសិតខាងលើនេះ មានចំណុចដ៏សំខាន់ ៣ យ៉ាងគឺៈ

១– ព្រមព្រៀងគ្នាប្រជុំ,

២– ព្រមព្រៀងគ្នាក្រោកចាកទីប្រជុំ,

៣– ព្រមព្រៀងគ្នាធ្វើកិច្ចការ ។

ត្រង់បទថាព្រមព្រៀងគ្នាប្រជុំ បានសេចក្តីថា អ្នកដែលត្រូវមកកាន់ទីប្រជុំនោះ បានមកដល់ព្រមព្រៀងគ្នា តាមពេលកំណត់ គឺថា ការប្រជុំម្តង ៗ សុទ្ធតែបានកំណត់ពេលទុកជាមុន ដូចបានកំណត់ថានៅថ្ងៃទី ១២ ខែឧសភា ព.ស. ២៥០០ វេលាម៉ោង ៧ ព្រឹក ត្រូវប្រជុំគ្នានៅទីព្រះសក្យមុនីចេតិយ ក្រុងភ្នំពេញ ។ អ្នកដែលត្រូវមកប្រជុំបានមកដល់មុនម៉ោង ៧ បន្តិច ឬក៏ត្រឹមម៉ោង ៧ គត់, បានជួបជុំព្រមគ្នា យ៉ាងនេះ ហៅថាព្រមព្រៀងគ្នាប្រជុំ ។ ការប្រជុំបែបនេះ ចាត់ថាជាការប្រជុំត្រឹមត្រូវ មានរបៀបរៀបរយ មិនរយីករយាក ។ ប្រសិនបើអ្នកដែលត្រូវមកប្រជុំនោះ បណ្តែតបណ្តោយទម្រន់ដំអក់ ដោយការធ្វេសប្រហែស មកក្រោយពេលកំណត់ឆ្ងាយពេក ឬមិនទាំងមកផង ដោយឥតឲ្យដំណឹងមុន, បើមកខុសពេលតែម្នាក់ ក៏មិនជាអ្វីប៉ុន្មាន ប្រសិនបើមកខុសពេលច្រើនគ្នា ឬមិនមកច្រើនគ្នា ទីប្រជុំនោះអាចចាត់ទុកថាជាទីប្រជុំមិនព្រមព្រៀងគ្នា ក្លាយទៅជារយីករយាកទ្វិធា ។ ការប្រជុំបែបនេះនឹងមិនឋិតថេរយូរទៅមុខបានឡើយ នឹងត្រូវវិនាសបាត់ ក្នុងអនាគត

ដ៏ទី ដោយហេតុថា ការប្រជុំខ្វះខាតសាមគ្គីធម៌ គឺច្បាប់ ឬ កម្រិត ព្រមព្រៀងគ្នា ។ ប្រសិនបើការប្រជុំនោះ មិនវិនាសបាត់ទៅទេ ដោយអ្នកចាត់ការមានព្យាយាម បេះតែបន្តកិច្ចប្រជុំនោះទៅទៀត ប៉ុន្តែអ្នកដែលត្រូវមកប្រជុំ នៅតែមិនអាចធ្វើការប្រជុំនោះ ឲ្យព្រមព្រៀង ឲ្យត្រឹមត្រូវតាមពេលវេលាបានទេ ទីប្រជុំនោះចាត់ថាជាទីប្រជុំយើករយាកខ្ជិលខ្ជា ឥតតម្លៃថ្លៃថ្នូរ ជាទីប្រជុំធូរថយសាបរលាប មិនអាចឲ្យចម្រើនផលសមតាមប្រាថ្នាបានឡើយ ដូចពុទ្ធភាសិតថា

យំ កិញ្ចិ សិថិលំ កម្មំ ន តំ ហោតិ មហប្ផលំ

“ អំពើណាមួយ ដ៏ធូរថយ អំពើនោះ មិនអាចឲ្យសម្រេចផលដ៏ធំបានឡើយ ”, ដូច្នេះ ពួកបព្វជិតក្តី ពួកពុទ្ធបរិស័ទជាគ្រហស្ថក្តី ដែលមានអង្គការតម្រូវឲ្យមានការប្រជុំនោះ គួរខំប្រឹងចាត់ការប្រជុំ ឲ្យបានព្រមព្រៀងគ្នា ទើបជាហេតុ ទីងនាំឲ្យសម្រេចផលសមតាមបំណងបាន ។

គ្រង់បទថាព្រមព្រៀងគ្នាក្រោកចាកទីប្រជុំនោះ បានសេចក្តីថា អ្នកដែលមកប្រជុំតាំងប៉ុន្មាន បាននៅក្នុងទីប្រជុំរហូតដល់ផុតកិច្ចប្រជុំ ឬផុតកាលកំណត់ ទើបក្រោកចាកទីប្រជុំព្រមគ្នា ក្នុង

ឱកាសដែលអធិបតីនៃការប្រជុំ បានឲ្យដំណឹងថា អស់កិច្ចប្រជុំហើយ ៗ ប្រសិនបើការប្រជុំនោះមិនទាន់ចប់នៅឡើយទេ ប៉ុន្តែអ្នកដែលប្រជុំនោះ ខ្លះមានកិច្ចធុរៈមិនអាចគង់ត្រាំនៅបានរហូតដល់ទីបំផុត គួរជម្រាបអធិបតីឲ្យបានជ្រាបមុនហើយសឹមចេញទៅ ។ ក្នុងព្រះវិន័យ មានពុទ្ធប្បញ្ញត្តិហាមថា ៖

យោ បន ភិក្ខុ សង្ឃេ វិនិច្ឆយកថាយ វត្តមានាយ ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កមេយ្យ បាចិត្តិយំ “ភិក្ខុណាមួយ, បើជំនុំសង្ឃកំពុងវិនិច្ឆ័យសេចក្តី (អ្វីមួយ), ឥតបានឲ្យឆន្ទៈសោះ ហើយក្រោកចេញ (ពីទីប្រជុំនោះ) ទៅ, ត្រូវអាបត្តិបាចិត្តិយៈ”, ដូច្នេះ ការក្រោកចាកទីប្រជុំនោះ បើបានឲ្យដំណឹងមុន ក៏នៅក្នុងឋានៈព្រមព្រៀងគ្នាដដែល ។

ដែលហៅថាក្រោកចាកទីប្រជុំមិនព្រមព្រៀងគ្នានោះ គឺថា កំពុងតែប្រជុំ អ្នកខ្លះក្រោកចេញទៅឯណេះ ខ្លះទៅឯណោះ ឥតប្រាប់ដំណឹងអ្វីសោះ ធ្វើឲ្យទីប្រជុំនោះរយីករយាក ឥតមានរបៀបរៀបរយ ។ ការក្រោកចាកទីប្រជុំ មិនព្រមព្រៀងគ្នាយ៉ាងនេះ ជាហេតុនាំឲ្យការប្រជុំនោះឥតតម្លៃ ថែមទាំងមិនឲ្យមានដំណើរបើក

នៅបានអន្ទឹងផងទៀត ដោយហេតុអ្នកមកប្រជុំនោះ មានចិត្តកើតខ្លាយបន្តិចម្តង ៗ មិនយូរប៉ុន្មាន ការប្រជុំនោះក៏នឹងវិនាសបាត់ទៅ ។

ដូច្នេះ គួរពួកបញ្ញវន្ត ពួកពុទ្ធបរិស័ទជាគ្រហស្ថ ដែលមានអធិការណាមួយតម្រូវឲ្យមានការប្រជុំ គប្បីចាត់របៀបការប្រជុំនោះឲ្យរៀបរយ ឲ្យបានរួបរួមព្រមព្រៀងគ្នា រហូតដល់ចប់កិច្ចប្រជុំសឹមក្រោកដោយព្រមព្រៀងគ្នាតែម្តង ដូច្នេះ ជាកិច្ចប្រសើរល្អណាស់ ព្រោះនាំឲ្យការប្រជុំនោះមានតម្លៃល្អផង នាំឲ្យការប្រជុំនោះមានអាយុយឺនយូរផង ។

## កិច្ចពិសេស

ក្នុងឱកាសដែលកំពុងប្រជុំ អ្នកដែលមកកាន់ទីប្រជុំនោះ តើត្រូវធ្វើដូចម្តេច ? កិច្ចនេះមិនមានក្នុងពុទ្ធភាសិត ដែលបាននាំយកមកថ្លែងទុកជាបឋមមាតិកាខាងដើមនោះទេ ខ្ញុំសូមថ្លែងសេចក្តីបន្តិចតាមយោបល់ដែលយល់ឃើញ ដោយធ្លាប់បានសង្កេត បានគិតទុកជាយូរមកហើយ ឃើញថាអ្នកដែលចូលមកកាន់ទីប្រជុំ គួរប្រតិបត្តិដូចតទៅនេះ៖

១– ការប្រជុំគ្នាស្ដាប់ធម៌ទេសនា, ស្ដាប់សន្និសីទ ឬស្ដាប់បាឋកថានោះ អ្នកមកប្រជុំត្រូវធ្វើឲ្យមានការស្ងប់ស្ងៀម ហើយប្រុងប្រយ័ត្នតាំងស្ដាប់ដោយយកចិត្តទុកដាក់ ។

២– ការប្រជុំដើម្បីពិនិត្យរឿងរ៉ាវផ្សេងៗ, ប្រជុំគិតបង្កើតការអ្វីមួយ, ប្រជុំគ្នាបញ្ចេញយោបល់រកគ្នា, ប្រជុំគ្នារិះរកគោលការណ៍ដើម្បីនឹងដោះបញ្ហាផ្សេងៗ ។ល។ ការប្រជុំមានប៉ុណ្ណេះជាដើម ពួកអ្នកដែលចូលមកប្រជុំ ត្រូវប្រតិបត្តិដូច្នេះ៖

ក) កុំនិយាយភាសាដទៃ ដែលអ្នកប្រជុំឯទៀតគ្នាស្ដាប់មិនបានទាំងអស់គ្នា ដើម្បីកុំឲ្យអ្នកស្ដាប់មិនបាននោះ មានសេចក្ដីរង្កៀសចិត្ត វៀរលែងតែក្នុងទីប្រជុំនោះ មានជនបរទេសដែលត្រូវប្រាស្រ័យជាមួយ ទោះបីដូច្នេះ ក៏គង់តែឲ្យមានអ្នកបកប្រែឲ្យស្ដាប់បានទាំងអស់គ្នាដែរ ឬពុំនោះ អ្នកដែលចូលមកកាន់ទីប្រជុំអាចស្ដាប់ភាសាដទៃនោះបានទាំងអស់គ្នា ។

ខ) កុំនិយាយខ្សិបខ្សៀវតែ ២ នាក់ ៣ នាក់ក្នុងទីប្រជុំ ព្រោះជាហេតុនាំឲ្យអ្នកដទៃមានសេចក្ដីរង្កៀសជិតចិត្ត ។

គ) ក្នុងឱកាសដែលអធិបតីទីប្រជុំ ផ្ដើមរឿងអ្វីឡើង, អ្នក

ប្រជុំត្រូវប្រុងស្តាប់ ហើយជួយត្រិះរិះដោយគំនិតប្រាជ្ញា ឲ្យឃើញហេតុនិងផលនៃរឿងនោះ ហើយជួយគិតរកផ្លូវ ឲ្យដំណើររឿងនោះ ៗ បានប្រព្រឹត្តទៅដោយស្រួល ។

ឃ) ក្នុងពេលកំពុងជំនុំពិភាក្សាពីរឿងអ្វីមួយ ៗ, អ្នកប្រជុំត្រូវបើកឱកាសឲ្យម្នាក់ ៗ និយាយតាមការយល់ឃើញរបស់ខ្លួន, មិនត្រូវដណ្តើមគ្នានិយាយ ឬ និយាយព្រមគ្នាពីរបីនាក់ឡើយ ត្រូវតែចាំស្តាប់គ្នាម្នាក់ម្តង ប៉ុន្តែ អ្នកដែលបានឱកាសនិយាយនោះសោត ក៏មិនត្រូវនិយាយច្រើនពេកតែម្នាក់ឯងដែរ ត្រូវទុកពេលឲ្យអ្នកឯទៀតនិយាយផង វៀរលែងតែអ្នកប្រជុំគេសុំឲ្យនិយាយតទៅទៀត ។

ង) ក្នុងពេលកំពុងប្រជុំពិភាក្សាគ្នានោះ អ្នកប្រជុំត្រូវបោះបង់ឡើងទោសចិត្តចេញ ហើយត្រូវតាំងចិត្តឲ្យល្អបរិសុទ្ធចំពោះកិច្ចការទាំងឡាយ ។

សេចក្តីប្រតិបត្តិទាំង ៥ ខាងលើនេះ នឹងនាំឲ្យការប្រជុំមិនខាតពេលវេលាផង មិនឲ្យរវៀសដិតចិត្តរវាងគ្នានិងគ្នាផង ឲ្យបានសម្រេចកិច្ចការដែលត្រូវពិគ្រោះប្រឹក្សាគ្នានោះផង ។

ត្រង់បទថា ព្រមព្រៀងគ្នាធ្វើកិច្ចការរបស់សង្ឃនោះ បាន សេចក្ដីថា កិច្ចការរបស់សង្ឃត្រូវតែសង្ឃធ្វើដោយព្រមព្រៀងគ្នា ។ ពាក្យថាសង្ឃក្នុងទីនេះ ចំពោះយកគណៈសង្ឃជាបព្វជិត ជាអ្នក បួសក្នុងព្រះពុទ្ធសាសនា គឺបព្វជិតតាំងពី ៤ រូបឡើងទៅ ហៅថា សង្ឃ ។ កិច្ចការរបស់សង្ឃមានច្រើនយ៉ាង មានឧបោសថកម្មនិង បវារណាកម្មជាដើម សុទ្ធតែជាកិច្ចដែលភិក្ខុសង្ឃត្រូវធ្វើដោយព្រម ព្រៀងគ្នា ។ ក្នុងវិនយបិដក មានពុទ្ធប្បញ្ញត្តិថា ភិក្ខុរូបណាមិន អើពើនឹងកិច្ចការរបស់សង្ឃ ភិក្ខុរូបនោះ ត្រូវទុកជាបត្តិ ។

ខំករុណា អាត្មាយល់ឃើញថា ព្រះពុទ្ធភាសិតក្នុងទីនេះពិត ជាចំពោះលើគណៈសង្ឃខាងព្រះពុទ្ធសាសនាក៏មែនហើយ ប៉ុន្តែ តាមពុទ្ធភាសិតនេះ បើពុទ្ធបរិស័ទជាគ្រហស្ថយកមកប្រតិបត្តិតាម ផង ក៏ជាកិច្ចប្រសើរណាស់ ព្រោះពាក្យថា "សង្ឃ" មួយម៉ាត់ នេះ បានអធិប្បាយខាងដើមរួចមកហើយ; គឺពាក្យថាសង្ឃៈនេះ ប្រែថា ពួកឬក្រុម, មនុស្សដែលមានគ្នាច្រើន តាំងពី ៤ នាក់ឡើង ទៅហៅថាពួកឬក្រុម, បើភាសាបាលីថា សង្ឃៈ, កិច្ចការដែល មនុស្សមានគ្នាច្រើនត្រូវធ្វើ ហៅថា សង្ឃករណីយកិច្ចក៏បាន ដូច

ជាកិច្ចដែលភិក្ខុសង្ឃត្រូវធ្វើនោះដែរ ។ ដូចជាសមាគមមួយ ៗ ដែលមានសមាជិក-សមាជិកា រួបរួមគ្នាបង្កើតឡើង ហើយបាន ជ្រើសរើសពួកសមាជិកសមាជិកា តាំងឲ្យជាក្រុមអភិបាលរបស់ សមាគម, ក្រុមអភិបាលនោះ មានគ្នាចំនួន ១២ នាក់ ឬ ១៥ នាក់ ជាអ្នកមានភារៈខាងចាត់ចែងកិច្ចការរបស់សមាគម ឲ្យមានដំណើរ ប្រព្រឹត្តទៅកាន់សេចក្តីចម្រើន ។ ប្រសិនបើក្រុមអភិបាលនោះធ្វើ ការដោយមិនព្រមព្រៀងគ្នា សមាគមនោះ ក៏នឹងមិនមានដំណើរ ប្រព្រឹត្តទៅស្រួលបានឡើយ លុះតែក្រុមអភិបាលបានព្រមព្រៀង គ្នាប្រជុំ ព្រមព្រៀងគ្នាធ្វើការ ទើបកិច្ចការរបស់សមាគមនោះ ៗ នឹងអាចប្រព្រឹត្តទៅកាន់សេចក្តីចម្រើនបាន ។

សេចក្តីដែលសំដែងមកតាំងប៉ុន្មានខាងលើនេះ គឺសំដែងអំពី សាមគ្គី ការព្រមព្រៀងគ្នា របស់ពួកក្រុមនីមួយ ៗ តាំងខាងផ្នែក បព្វជិត តាំងខាងផ្នែកគ្រហស្ថជាពុទ្ធបរិស័ទ ។ ចំណែកខាងកិច្ច ការដែលត្រូវធ្វើដោយព្រមព្រៀងគ្នានោះ ចំពោះតែកិច្ចការដែលត្រូវ ល្អប្រពៃ ជាការបុណ្យកុសល ឬជាកិច្ចការដែលមានប្រយោជន៍ ដល់ព្រះពុទ្ធសាសនា, ដល់ប្រទេសជាតិឬដល់ខ្លួន ៗ កិច្ចការតាំង

នោះ ទើបសម្រេចបានដោយស្រួល ហើយទើបបញ្ចេញផលផ្ដល់សេចក្ដីសុខ-ចម្រើនដល់អ្នកធ្វើ ។ ចុះប្រសិនបើកិច្ចការដែលធ្វើដោយព្រមព្រៀងគ្នានោះ ជាអំពើបាបអកុសល ជាអំពើនាំឲ្យខូចដល់ព្រះពុទ្ធសាសនា, ដល់ប្រទេសជាតិ, ដល់ពួកក្រុម ឬដល់ខ្លួន តើកិច្ចការនោះសម្រេចឬមិនសម្រេច ក៏គង់ទើបសម្រេចបានខ្លះ ដោយការព្រមព្រៀងគ្នា ប៉ុន្តែកិច្ចការទាំងនោះ បើសម្រេចបានប៉ុន្មាន សុទ្ធតែនាំឲ្យបានទុក្ខព្រួយដល់ខ្លួន, ដល់ពួកក្រុមរបស់ខ្លួនមិនខាន ព្រោះអំពើអាក្រក់ អំពើខុសទាំងនោះ ច្បាប់ខាងព្រះពុទ្ធសាសនា និងច្បាប់សម្រាប់ប្រទេស តែងហាមប្រាមមិនឲ្យធ្វើដោយដាច់ខាត មិនដែលអនុញ្ញាតបើកឲ្យធ្វើឡើយ ។

សេចក្ដីថ្លែងអំពីសាមគ្គី ដោយនាំយកពុទ្ធភាសិត មកតម្កល់ជាគោល ព្រមទាំងសេចក្ដីអធិប្បាយ តាមយោបល់ដែលយល់ឃើញខ្លះជាសេចក្ដីសង្ខេប សូមសន្មតថាចប់ត្រឹមប៉ុណ្ណេះ ។

*

* *

លំដាប់តទៅនេះ ទើបថ្លែងអំពីសាមគ្គីភេទ គឺការបែកនៃសាមគ្គី ដូចមានសេចក្ដីតទៅនេះ :

# សាមគ្គីភេទ

ការបែកធ្លាយនៃសាមគ្គីធម៌ របស់ពួកជនក្នុងសង្គមមួយ ១ រវាងគ្នានិងគ្នា ហៅថា "សាមគ្គីភេទ" ។

មនុស្សអ្នកបំបែកសាមគ្គី ឬ ទម្លុះទម្លាយនូវសាមគ្គីរបស់ពួកជនក្នុងសង្គមមួយៗ ឲ្យបែកបាក់គ្នា ហៅថា "សាមគ្គីភេទកៈ" ។

ឥឡូវនេះ នឹងពោលអំពីពាក្យថា "សង្គម" ជាមុន រួចនឹងពោលអំពីការបែកសាមគ្គី និងផលអាក្រក់ ដែលកើតអំពីការបែកសាមគ្គីតទៅទៀត ។

ជនទាំងឡាយគ្រប់ប្រភេទ នៅក្នុងប្រទេសកម្ពុជាយើងនេះ ដែលរួបរួមគ្នាជាពួកជាក្រុម ហៅថា "សង្គម" ។ នោះមានច្រើនប្រភេទទៅទៀត ជាសង្គមតូច សង្គមកណ្ដាល និងសង្គមធំ តាមចំនួនមនុស្សតិចច្រើន ក្នុងសង្គមមួយ ១ ។ គ្រួសារមួយ ១ ដែលមានស្វាមី ភរិយា និងកូនប្រុស-ស្រី នៅរួមជាមួយគ្នា ហៅថាសង្គមតូច ។ សង្គមតូច ១ នៅផ្ដុំគ្នាច្រើនក្នុងទីណា ទីនោះហៅថាភូមិ ចាត់ជាសង្គម ១ ។ ភូមិច្រើនផ្ដុំគ្នាឡើង ហៅថា ឃុំ ចាត់ជាសង្គម ១ ។ ឃុំច្រើនរួមជាមួយគ្នា ហៅថា ស្រុក ចាត់ជា

សង្គម ១ ៗ ស្រុកច្រើនផ្ដុំឡើងរួមគ្នា ហៅថា ខែត្រ ចាត់ជាសង្គម ១ ៗ ខែត្រច្រើន រួមគ្នាហៅថារដ្ឋ ឬ ហៅថាប្រទេស ចាត់ជាសង្គម ១ ៗ

មួយទៀត ពួកឬក្រុមជនដែលរួបរួមគ្នាជាសមាគមមួយ ១ ក៏ហៅថាសង្គមមួយ ១ ដែរ ពុំនោះដូចជាសាលារៀនមួយ ១ ដែលមានបុគ្គលិកសាស្ត្រាចារ្យ និងនិស្សិតតិចក្ដី ច្រើនក្ដី ក៏ហៅថាសង្គមមួយ ១ ដែរ ៗ

ឯការបែកសាមគ្គី បានសេចក្ដីថា ការរួបរួមគ្នាជាសង្គមបាក់បែកអស់ហើយ គឺគ្មានការរួបរួមគ្នាទេ មានតែការមិនទុកចិត្តគ្នា ឈ្លោះទាស់ទែងគ្នា រករឿងគ្នាទៅវិញទៅមក និយាយដើមគ្នាពីរឿងអាក្រក់ទៅវិញទៅមក រករឿងប្រឆាំងគ្នាទៅវិញទៅមក ។ល។

មនុស្សដែលនៅក្នុងសង្គមមួយ ១ សូម្បីក្នុងសង្គមដ៏តូចបំផុតដូចជាក្នុងគ្រួសារមួយ ១ កាលបើបែកសាមគ្គីរវាងគ្នានិងគ្នាហើយ គ្រួសារនោះត្រូវទទួលផលអាក្រក់ គឺឥតមានសេចក្ដីសុខ សេចក្ដីចម្រើនទេ មានតែទុក្ខព្រួយលំបាកចិត្តជានិច្ចនិរន្តរ៍, ជួនកាលឈ្លោះ

ប្រកែកគ្នារហូតដល់ទៅបាក់បែកលែងលះគ្នាក៏មាន ជួនកាលកើតរឿងក៏ធំរហូតដល់រលាយគ្រួសារនោះទៅក៏មាន ។

មនុស្សដែលអាស្រ័យនៅក្នុង ភូមិ ឃុំ ស្រុក ខេត្ត និងក្នុងប្រទេសដែលចាត់ជាសង្គមមួយ ៗ តាមចំនួនមនុស្សតិចច្រើននោះ កាលបើបែកសាមគ្គីរវាងគ្នានិងគ្នាហើយ គឺថា បែកបាក់គ្នាហើយ មិនអាចរួបរួមគ្នា ដោយកាយ វាចា និងចិត្ត ហើយមិនទុកចិត្តគ្នា ចេះតែរករឿងរកហេតុទៅវិញទៅមក សង្គមនោះ ៗ ឥតមានសេចក្ដីសុខចម្រើនទេ មានតែការវិនាសហិនហោចបន្តិចម្ដង ៗ រហូតដល់រលាយរលត់ទៅក៏មាន ។

ក្នុងការបែកសាមគ្គី ដែលរមែងឲ្យផលអាក្រក់ គឺសេចក្ដីវិនាសហិនហោចនោះ គួរនាំយករឿងមួយ ដែលមានក្នុងគម្ពីរព្រះពុទ្ធសាសនាមកថ្លែងបញ្ជាក់ ដោយសង្ខេប ទុកជាឧទាហរណ៍សម្រាប់ពិចារណា ដូចមានតទៅនេះ :

មានរដ្ឋ ១ ឈ្មោះវជ្ជី មានពួកក្សត្រលិច្ឆវី ជាអ្នកគ្រប់គ្រង, ក្សត្រទាំងនោះព្រមទាំងមន្ត្រី បណ្ដារាស្ត្រ និងយុវជនដែលសិក្សាក្នុងសាលារៀន មានសាមគ្គីព្រមព្រៀងគ្នាល្អណាស់ ៗ ក្នុងដែន

ផ្ទៃនោះ មានការប្រជុំគ្នាញឹកញយណាស់ ពិនិត្យមើលកិច្ចការផែនដីតាំងមូល ព្រមទាំងមានការគោរពគ្នាទៅវិញទៅមក ចេះរក្សាបវេណីធម៌យ៉ាងប្រសើរ ម្ល៉ោះហើយផែនដីនោះមានកិត្តិយសកេរ្តិ៍ឈ្មោះ ផ្សាយចេញឮសាយសុសដល់ប្រទេសនានា ថា ផែនដីជាប្រទេសមានសាមគ្គីមាំមួនណាស់ ឥតមានសត្រូវណានឹងចូលទៅលុកលុយបាន ។ ព្រះបាទអជាតសត្តុរាជ សោយរាជ្យនៅក្នុងដែនមគធៈ ជាប្រទេសធំស្តុកស្តម្ភ មានព្រះរាជបំណងនឹងលើកទ័ពទៅវាយផែនដីនោះឲ្យខ្ទេចខ្ទី ដោយមានគំហឹងចំពោះពួកស្តេចលិច្ឆវី ក្នុងរឿងសេដ្ឋកិច្ចជាយូរហើយ ប៉ុន្តែពុំអាចនឹងលើកទ័ពចូលទៅបាន ព្រោះបានឮដំណឹងថា ក្នុងផែនដីនោះ ពួកក្សត្រលិច្ឆវីមន្ត្រីនិងបណ្ដារាស្ត្រ មានសាមគ្គីព្រមព្រៀងគ្នា ចងបាច់គ្នាមាំមួនណាស់ ។ ទើបព្រះបាទអជាតសត្តុរាជ ទ្រង់រិះរកមធ្យោបាយផ្សេងៗ ដើម្បីនឹងលើកទ័ពទៅវាយផែនដីនោះ ឲ្យបានដោយងាយ ៗ តមក ទ្រង់បានសម្រេចព្រះរាជហឫទ័យថា ត្រូវធ្វើនយោបាយសម្ងាត់ ដើម្បីបំបាក់បំបែកសាមគ្គី របស់ពួកស្តេចលិច្ឆវីឲ្យបានមុនសិនសឹមលើកទ័ពទៅវាយជាខាងក្រោយ ។ លុះសម្រេចព្រះរាជ-

ហឫទ័យដូច្នេះហើយ ទ្រង់បានចាត់ប្រើវស្សការព្រាហ្មណ៍ជាវិនិច្ឆ-យាមាត្យ ជាអ្នកនយោបាយសំខាន់ម្នាក់ឲ្យទៅបំបាក់បំបែកក្នុងដែនវជ្ជី ប៉ុន្តែ ប្រើឧបាយកលធ្វើជាចាប់ទោសវស្សការព្រាហ្មណ៍នោះហើយដេញចេញអំពីដែនមគធៈ ដើម្បីឲ្យពួកក្សត្រក្នុងដែនវជ្ជីទទួលវស្សការព្រាហ្មណ៍នោះឲ្យនៅក្នុងដែនវជ្ជីដោយឥតរង្កៀស ។ កាលបើវស្សការព្រាហ្មណ៍ទៅដល់ដែនវជ្ជី ពួកក្សត្រលិច្ឆវី ក្រោយដែលបានដឹងថា ព្រាហ្មណ៍នោះ ត្រូវព្រះបាទអជាតសត្តុរាជបណ្ដេញចេញ ក៏ទទួលវស្សការព្រាហ្មណ៍នោះ ឲ្យនៅដោយសុខស្រួលព្រមទាំងឲ្យឋិតនៅក្នុងតំណែងជាវិនិច្ឆយាមាត្យ ដូចជាកាលនៅក្នុងដែនមគធៈ ។ វស្សការព្រាហ្មណ៍មុនដំបូងបានធ្វើការថ្វាយចំពោះក្សត្រលិច្ឆវីដោយយកចិត្តទុកដាក់ ហាក់ដូចជាមានការស្មោះត្រង់ណាស់ចំពោះដែនវជ្ជី នាំឲ្យពួកក្សត្រលិច្ឆវីពេញព្រះរាជហឫទ័យឥតមានរង្កៀសអ្វីសោះឡើយ ហើយបានតាំងប្រគល់ឋានៈជាអ្នកបង្ហាត់បង្រៀនវិជ្ជាផ្សេងៗ ដល់ពួកយុវលិច្ឆវីក្សត្រទាំងឡាយផងទៀត ។ វស្សការព្រាហ្មណ៍ បានដឹងថាពួកក្សត្រលិច្ឆវីឥតមានសេចក្ដីរង្កៀសអ្វីនឹងខ្លួន ឃើញថាពួកក្សត្រទាំងនោះមានការរួស

ប្រហែសហើយ ក៏ចាប់ផ្ដើមធ្វើការវិទ្ធង្សនាបំបាក់បំបែក តាំងពីយុវជនដែលកំពុងសិក្សា ដោយវិធីខ្សឹបខ្សៀវនឹងយុវជន ១ នាក់ ៗ រាល់ថ្ងៃ បណ្ដាលឲ្យពួកយុវជនកើតមានសង្ស័យអស់ជំនឿលើគ្នា បន្តិចម្ដង ៗ យូរទៅ ៗ ពួកក្មេង ៗ ក៏បែកគ្នាជាបក្ខជាពួក យូរ ៗ ទៅទៀតក្សត្រមន្ត្រីក៏បែកបាក់គ្នា តទៅទៀត ពួកប្រជាពលរដ្ឋក៏បែកបាក់គ្នាទៀត កើតទៅជាបក្សពួក លែងជឿគ្នាទៅវិញទៅមក រហូតដល់ទៅក្នុងដែនវជ្ជី បែកសាមគ្គីលែងរួបរួមគ្នាកើត ៗ

ព្រះបាទអជាតសត្តុរាជ កាលបើបានជ្រាបថា ក្នុងដែនវជ្ជីនោះ មានការបែកបាក់សាមគ្គីអស់ហើយ ឥតមានការរួបរួមគ្នាដូចកាលមុនទេ ក៏លើកទ័ពចូលទៅវាយដែនវជ្ជីនោះ បានសម្រេចដូចបំណងភ្លាម ៗ ។

និទានកថាសង្ខេបខាងលើនេះ គួរជនទាំងឡាយគ្រប់សង្គមដែលប្រាថ្នាចង់បានសេចក្ដីសុខ-ចម្រើន គប្បីតែងពិចារណាយកទុកជាឧទាហរណ៍ ហើយប្រុងប្រយ័ត្នរក្សាសាមគ្គីឲ្យមាំមួន កុំឲ្យបែកបាក់គ្នាឲ្យសោះ បើទុកជាមានហេតុអ្វីកើតឡើងក្នុងសង្គម ជាហេតុគួរឲ្យមានទោមនស្ស គួរឲ្យឈឺចាប់ក្នុងចិត្ត ដែលបណ្ដាលកើតមក

អំពីពួកជនក្នុងសង្គមជាមួយ ឬ អំពីជនដទៃដែលជាសាមគ្គីភេទកៈ ត្រូវតែខំប្រឹងទប់ចិត្តអត់ធន់ចំពោះហេតុនោះ ៗ បាន ហើយត្រូវប្រុងស្មារតីប្រយ័ត្ន គិតពិចារណាឲ្យទាន់ពេល កុំឲ្យសង្គមរបស់ខ្លួនប្រេះឆាបាក់បែកកុំឲ្យធ្លាក់ទៅក្នុងសាមគ្គីភេទ ទោះបីមានហេតុដ៏ធ្ងន់យ៉ាងណាក៏ដោយ ត្រូវតែខំប្រឹងទប់ទល់រក្សាសង្គមរបស់ខ្លួន ឲ្យមានសាមគ្គីជាដរាបតទៅ ព្រោះការបែកសាមគ្គីក្នុងសង្គមនីមួយ ៗ នាំឲ្យមានផលអាក្រក់ច្រើនយ៉ាងណាស់គឺ :

– សុខកាយសប្បាយចិត្តរលាយអស់ ទុក្ខព្រួយលំបាកកើតឡើង,
– សង្គមរបស់ខ្លួន ខ្សោយកម្លាំង មានសត្រូវប្រឆាំងកាន់តែច្រើន;
– ពួកជនក្នុងសង្គម មានចិត្តក្តៅក្រហាយជានិច្ច,
– កិត្តិយសនិងកេរ្តិ៍ឈ្មោះរបស់សង្គមត្រូវអាប់ឱន,
– កិច្ចការរបស់ជនក្នុងសង្គម តែងជួបនឹងឧបសគ្គផ្សេង ៗ,
– ជួនកាលសង្គមរបស់ខ្លួនត្រូវរលាយរលត់ទៅក៏មាន,

ផលអាក្រក់មានប៉ុណ្ណេះជាដើម កើតឡើងអំពីការបែកសាមគ្គី ។

*
*   *

# សាមគ្គីភេទខាងព្រះពុទ្ធសាសនា

ចំណែកការបែកសាមគ្គីខាងព្រះពុទ្ធសាសនាវិញ មានសេចក្ដីដូចតទៅនេះ :

វត្តអារាមមួយ ៗ ដែលមានភិក្ខុ-សាមណេរគិចក្ដី ច្រើនក្ដីអាស្រ័យនៅជាប្រក្រតី ក្រោមការត្រួតត្រានៃលោកចៅអធិការ ១ រូប ហៅថាសង្គម ១ ៗ សង្គមនៃព្រះភិក្ខុសង្ឃនេះ ដែលឋិតនៅក្រោមឱវាទនៃព្រះពុទ្ធជាអម្ចាស់ បើព្រះភិក្ខុសង្ឃទាំងអស់ មានសន្តានចិត្តប្រកបដោយធម៌ មានសាមគ្គី គឺការព្រមព្រៀងគ្នារើករាយនឹងគ្នា ធ្វើអ្វីក៏ព្រមព្រៀងគ្នា ចេះគោរពគ្នាតាមចាស់តាមក្មេង ចេះស្ដាប់បង្គាប់គ្នា ប្រសិនបើមានការគំនុំគំគួនរវាងគ្នានិងគ្នាខ្លះ ក៏ចេះអត់សង្កត់ចិត្ត ដើម្បីរក្សាសាមគ្គីឲ្យមាននៅក្នុងសង្គម គឺវត្តអារាមជាដរាបតទៅ, បើសង្គមនៃព្រះភិក្ខុសង្ឃក្នុងវត្តអារាម មានសាមគ្គីហើយ ពុទ្ធបរិស័ទជាញាតិញោមជើងវត្ត ក៏នឹងមានសាមគ្គីផងដែរ ព្រោះថា ប្រសិនបើញាតិញោមជើងវត្តណាមួយ ឈ្លោះតាស់ទែងគ្នានាំឲ្យបែកសាមគ្គី ព្រះសង្ឃក្នុងវត្តនឹងព្រួតគ្នាទូន្មាន ១ រំលឹកតាមផ្លូវធម៌ គ្រាន់តែញាតិញោមជើងវត្តនោះ បានជានាទីនឹងគ្នា

មានសាមគ្គីរវាងគ្នានិងគ្នា  វៀរលែងតែហេតុការណ៍ណា  ដែលភិក្ខុសង្ឃពុំអាចនឹងលូកដៃចូលបាន ។ បើមានសាមគ្គី  ទាំងព្រះសង្ឃក្នុងវត្ត  ទាំងពុទ្ធបរិស័ទចំណុះជើងវត្តយ៉ាងនេះហើយ  សេចក្ដីសុខនិងសេចក្ដីចម្រើន  នឹងកើតមានជាប្រាកដដល់ព្រះសង្ឃ  និងពុទ្ធបរិស័ទទាំងនោះ  ដោយទៀងទាត់ ។

ប្រសិនបើសង្គមព្រះសង្ឃ  ក្នុងវត្តអារាម  បែកសាមគ្គីវិញ  ដោយហេតុបណ្ដាលមក  អំពីលោកចៅអធិការជាអ្នកគ្រប់គ្រង  ពុំមានសមត្ថភាពក្នុងការគ្រប់គ្រងភិក្ខុ-សាមណេរ  ឬ  ពុំមាននាយកធម៌ប្រចាំនៅក្នុងខ្លួន  ឬក៏បណ្ដាលមក  អំពីភិក្ខុ-សាមណេរណាមួយជាសាមគ្គីភេទកៈ  ជាបុគ្គលពាល  ដែលមានចិត្តអាក្រក់  ព្រហើនកោងកាច  មើលងាយភិក្ខុ-សាមណេរផងគ្នា  មានមានះរឹងត្អឹងសម្គាល់ថាខ្លួនគ្រាន់បើជាងគេទាំងអស់  ឥតស្ដាប់បង្គាប់អ្នកណាមានចិត្តច្រណែនឈ្នានីស  បង្កបង្កើតឲ្យមានអធិករណ៍  កើតវិវាទទាស់ទែងគ្នា  រហូតដល់បែកបាក់សាមគ្គី  កើតទៅជាបក្សជាពួកក្នុងវត្ត ។  កាលបើសង្ឃក្នុងវត្តបែកបាក់គ្នាហើយ  ពួកពុទ្ធបរិស័ទជើងវត្ត  ក៏នឹងបែកបាក់គ្នាជាបក្សជាពួកផងដែរ  ដោយជួយកាន់ជើង,

ព្រះសង្ឃខាងនេះខាងនោះ ម៉្លោះហើយសង្គមព្រះសង្ឃក្នុងវត្តនោះ និងសង្គមពុទ្ធបរិស័ទជើងវត្តនោះ ក៏កើតទៅជាមានការអាប់អួរ រករឿងគ្នាទៅវិញទៅមក ទាំងសង្ឃទាំងគ្រហស្ថ ដូនកាលក៏កើតទៅជាមានរឿងហេតុប្តឹងផ្តល់អំពីគ្នា រកពេលចប់គ្មាន ។

កាលបើមានការបែកបាក់គ្នារវាងសង្ឃនិងសង្ឃ រវាងគ្រហស្ថនិងគ្រហស្ថ ឬរវាងសង្ឃនិងគ្រហស្ថយ៉ាងនេះហើយ សេចក្តីសុខគ្រប់យ៉ាងក្នុងទីវត្តនោះ ក៏រលាយអស់, សេចក្តីចម្រុងចម្រើនគ្រប់យ៉ាងក៏សាបសូន្យអស់ មានតែការវិនាសហិនហោចកើតឡើងគឺ៖

— ព្រះសង្ឃក្នុងវត្តកើតក្តៅក្រហាយក្នុងចិត្ត គិតតែរករឿងរកហេតុប្រទាំងយកឈ្នះរៀងខ្លួន ដោយឥតមានហិរិ និងឱត្តប្បៈក្នុងខ្លួនសោះឡើយ ។

— ព្រះសង្ឃក្នុងវត្តលែងយកចិត្តទុកដាក់ ក្នុងការសិក្សារៀនសូត្រ បោះបង់ការប្រតិបត្តិតាមគន្លងព្រះពុទ្ធសាសនាចោលអស់ ។

— ពុទ្ធបរិស័ទ ដែលធ្លាប់មានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភព្រះសង្ឃក្នុងវត្តនោះ ក៏ថយសទ្ធាជ្រះថ្លា ដែលនឹងជួយឧបត្ថម្ភគ្នាទៅទៀត ។

— ពុទ្ធបរិស័ទ ដែលឥតមានសទ្ធាជ្រះថ្លា ក៏ត្រឡប់ចិត្តកើតសេចក្តីស្អប់ខ្ពើមព្រះសង្ឃក្នុងវត្តនោះថែមទៀត ។

— ព្រះសង្ឃក្នុងវត្ត ក៏ទ្រាំយកម៉ាំងដោយខ្វះការឧបត្ថម្ភអំពីពុទ្ធបរិស័ទ នាំឲ្យអស់សមត្ថភាពក្នុងការរៀបចំទីសេនាសនៈក្នុងវត្តឲ្យបានល្អសមរម្យ និងក្នុងការជួសជុលទីសេនាសនៈ ដែលពុកផុះជ្រាយបាក់បែក ។

— កេរ្តិ៍ឈ្មោះវត្តនោះ និងកេរ្តិ៍ឈ្មោះព្រះភិក្ខុសង្ឃក្នុងវត្តនោះ មានចៅអធិការវត្តជាដើម ក៏ត្រូវអាប់ឱនចុះដោយត្រូវពុទ្ធបរិស័ទទាំងឡាយដែលមានហិរិឱត្តប្បៈ ពោលទោសគរហានិន្ទាយ៉ាងជូរចត់ថា មិនសមជាសមណៈក្នុងព្រះពុទ្ធសាសនាឡើយ ។

— ចំណែកពុទ្ធបរិស័ទជាចំណុះជើងវត្ត ដែលមានព្រះសង្ឃបាក់បែកគ្នានោះ ក៏លែងបានទទួលនូវសេចក្តីសុខ-ចម្រុងចម្រើនតាមឋានៈរបស់ខ្លួនជាគ្រហស្ថដែរ ដោយពុទ្ធបរិស័ទទាំងនោះ មានកង្វល់ក្នុងចិត្តគិតតែរករឿងប្រទូស្តគ្នាទៅវិញទៅមក ក្នុងរឿងជួយព្រះសង្ឃខាងនេះខាងនោះ ។

ដោយហេតុដូចខាងលើនេះ គួរបព្វជិតទាំងឡាយ គ្រប់វត្ត

អាកាម កុំបណ្ដាលឲ្យមានជម្លោះទាស់ទែងគ្នាឲ្យសោះ ព្រោះជម្លោះជាមូលដ្ឋាននៃការបែកសាមគ្គី គួរតែនឹករឭកឲ្យឃើញនូវព្រះបរម-ពុទ្ធោវាទ ដែលព្រះពុទ្ធជាព្រះបរមគ្រូ ទ្រង់ប្រោសប្រទានដល់ពួកភិក្ខុដែលនៅក្នុងក្រុងកោសម្ពី ដែលកំពុងឈ្លោះគ្នា កំពុងដណ្ដើមប្រជែងយកឈ្នះគ្នាថា: "អលំ ភិក្ខវេ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទំ" ម្នាលភិក្ខុទាំងឡាយ, កុំឡើយ, កុំបង្កហេតុ កុំឈ្លោះគ្នា កុំប្រកាន់ផ្សេង ៗ គ្នា កុំវិវាទនឹងគ្នាឡើយ"

ម្យ៉ាងទៀត, កាលព្រះបរមគ្រូទ្រង់ទូន្មានដូចខាងលើនេះអស់រយៈ ២ ដងហើយ ពួកភិក្ខុអ្នកបង្កជម្លោះមិនព្រមស្ដាប់តាម ទើបព្រះអង្គទ្រង់នាំ នូវអតីតនិទានពីព្រេងនាយ អំពីរឿងទីឃាវុកុមារឲ្យភិក្ខុទាំងនោះស្ដាប់ទៀត លុះចប់ហើយ ព្រះអង្គត្រាស់ថា: "តេសំ ហិ ញាម ភិក្ខវេ ភវតំ អាទិន្នទណ្ឌានំ អាទិន្នសត្ថានំ ឯវរូបំ ខន្តិសោរច្ចំ ភវិស្សតិ ។ ឥធ ខោ បន តំ ភិក្ខវេ សោភេថ យំ តុម្ហេ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា ខមា ច

កវេយ្យា៩ សោរតា ៤ ។ “ ម្នាលភិក្ខុទាំងឡាយ, គួរ
គោរពដែរ, ដូចពួកក្សត្រទាំងនោះ ធ្លាប់តែកាន់ដំបង ធ្លាប់តែកាន់
គ្រឿងសាស្ត្រាវុធ ហើយបេះអត់ធន់ និងបេះត្រេកអរក្នុងសុចរិត-
ធម៌មានសភាពយ៉ាងនេះបាន ។ ម្នាលភិក្ខុទាំងឡាយ, ចំណែក
អ្នកពល់គ្នាសុទ្ធតែបានបួសក្នុងធម៌វិន័យ ដែលតថាគតបានសំដែង
ដោយល្អយ៉ាងនេះហើយ គួរគប្បីតែអ្នកពល់គ្នាខំអត់ធន់ និងត្រេក-
អរក្នុងសុចរិតធម៌ ! ” ។

បព្វជិតទាំងឡាយក្នុងសម័យបច្ចុប្បន្ននេះ កាលបើបានទឹក
ត្រាស់ឃើញនូវព្រះបរមពុទ្ធោវាទ ដូចខាងលើនេះហើយ គួរគប្បី
តម្កល់នូវសតិសម្បជញ្ញៈ ឲ្យបរិបូណ៌ ហើយខំប្រឹងអត់សង្កត់ចិត្ត
រក្សាចិត្តឲ្យល្អ ចំពោះហេតុការណ៍ទាំងឡាយដែលកើតឡើង បម្រុង
នឹងឲ្យមានការវិវាទឈ្លោះប្រកែកគ្នា ដែលជាមូលដ្ឋាននៃការបាក់
បែកសាមគ្គីរវាងបព្វជិតនិងបព្វជិត ក្នុងព្រះពុទ្ធសាសនា ដើម្បីរក្សា
សាមគ្គីឲ្យបានឋិតនៅជាស្ថាពរតរៀងទៅក្នុងអនាគត ។

* * *

លំដាប់អំពីនេះ នឹងសំដែងអំពីសាមគ្គីភេទកៈ គឺបុគ្គលអ្នកបំបែកសាមគ្គី ដូចមានសេចក្ដីតទៅនេះ :

## សាមគ្គីភេទកៈ

ជនណាមួយជាបព្វជិតក្ដី គ្រហស្ថក្ដី ដែលមានចិត្តអាក្រក់ បំបាក់បំបែកសាមគ្គីនៃពពួកជនក្នុងសង្គមណាមួយ ទោះជាសង្គមព្រះសង្ឃខាងព្រះពុទ្ធសាសនាក្ដី សង្គមគ្រហស្ថក្ដី ឲ្យបាក់បែកគ្នា គឺឲ្យលែងរួបរួមគ្នាកើត ឲ្យលែងស្រឡាញ់រាប់អានគ្នាកើត ជននោះហៅថា "សាមគ្គីភេទកៈ", បើជាស្រីហៅថា "សាមគ្គីភេទិកា" ។

ជនអ្នកបំបាក់បំបែកសាមគ្គី ឈ្មោះថា ជាអ្នកធ្វើនូវអំពើបាបដ៏ធំក្រៃលែង ព្រោះអំពើនេះ នាំឲ្យមនុស្សមានចំនួនច្រើន បានទទួលនូវសេចក្ដីទុក្ខព្រួយផង នាំឲ្យគេខាតផលប្រយោជន៍ច្រើនផង នាំឲ្យគេកើតការក្ដៅក្រហាយចិត្តផង នាំឲ្យគេដល់នូវសេចក្ដីវិនាសហិនហោចប្រាសចាកសេចក្ដីសុខចម្រើនផង ។ ដូច្នេះ អ្នកបំបាក់បំបែកសាមគ្គី នឹងត្រូវបានទទួលនូវផលអាក្រក់ ដែលកើតឡើងពីអំពើអាក្រក់ដែលខ្លួនបានធ្វើនោះ ពុំខានឡើយ ។

មានពុទ្ធភាសិតថា :

អត្តនា វ កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

អំពើបាប ជនណាធ្វើដោយខ្លួនឯង ជននោះកាលទៅទទួលទុក្ខក្នុងអបាយទាំង ៤ នឹងលំបាក ឬសៅហ្មង ដោយខ្លួនឯង ។ អំពើបាប ជនណាមិនធ្វើដោយខ្លួនឯង ជននោះកាលដែលដល់នូវសុគតិផង នូវព្រះនិព្វានផង តែងសុខស្រួលឬបរិសុទ្ធ ដោយខ្លួនឯងក៏ក្នុងលោកនេះ ។ សេចក្តីបរិសុទ្ធ គឺកុសលកម្ម និងសេចក្តីមិនបរិសុទ្ធ គឺអកុសលកម្ម តែងឲ្យផលចំពោះខ្លួនជនអ្នកធ្វើ ជនដទៃមិនអាចញុំាងជនដទៃឲ្យស្អាតបរិសុទ្ធ ឬឲ្យសៅហ្មងបានឡើយ ។

មានពុទ្ធភាសិតម្យ៉ាងទៀតថា :

កល្យាណការី កល្យាណំ បាបការី ច បាបកំ
កម្មុនា វត្តតី លោកោ កម្មំ សត្តេ វិភជតិ
យទិទំ ហីនប្បណីតតាយ ។

អ្នកធ្វើអំពើល្អ តែងតែទទួលផលល្អ អ្នកធ្វើអំពើអាក្រក់ តែង

តែទទួលផលអាក្រក់ សត្វលោក តែងវិលចុះវិលឡើងដោយសារ
កម្ម កម្មគឺអំពើដែលសត្វណា ៗ ធ្វើ តែងតែចែកសត្វនោះ ៗ ឲ្យ
មានឋានៈទាបថោកនិងឋានៈខ្ពង់ខ្ពស់ ។

ដូច្នេះ គួរបព្វជិតនិងគ្រហស្ថទាំងឡាយ ដែលមានប្រាថ្នាចង់
បានសេចក្ដីសុខ-ចម្រើន គប្បីចៀសវាងអំពើបំបាក់បំបែកសាមគ្គី
ឲ្យផុតស្រឡះ ព្រោះការបំបាក់បំបែកសាមគ្គីនេះ សូម្បីធ្វើតែ ១ថ្ងៃ
ឬ ១ពេលក៏ដោយ អំពើនេះមានពិសណាស់ អាចនឹងផ្ដល់ទោស
ដល់អ្នកធ្វើនោះដោយឥតសំច័យ ឥតត្រាប្រណីឡើយ ។

សូមនាំយករឿងនិទានកថា ១ ដែលមានក្នុងអដ្ឋកថាធម្មបទ
មកថ្លែងជាសេចក្ដីសង្ខេបទុកក្នុងទីនេះ សម្រាប់បញ្ជាក់អំពីទោស
នៃអ្នកបំបាក់បំបែកសាមគ្គី ដូចមានតទៅនេះ :

មានរឿងដំណាលថា ក្នុងពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធទ្រង់
ព្រះនាមកស្សបៈ មានភិក្ខុ ២រូប ជាមិត្រសំឡាញ់នឹងគ្នា មាន
សាមគ្គីរួបរួមគ្នាខ្លាំងណាស់ ប្រាកដដូចជាបងប្អូនចេញពីផ្ទៃនៃមាតា
ជាមួយគ្នា ។ មានកាល ១ថ្ងៃ ភិក្ខុទាំងពីររូបនោះបបួលគ្នាថានឹង
ទៅកាន់រោងឧបោសថ ហើយក៏ចេញពីទីលំនៅរបស់ខ្លួនទៅ ដើម្បី

នឹងរួមធ្វើឧបោសថកម្ម ជាមួយនឹងភិក្ខុទាំងឡាយ ដែលគេប្រជុំគ្នា ក្នុងពេលធ្វើឧបោសថ ។ ក្នុងពេលនោះមានទេវតា ១ នៅក្នុងឋានតាវត្តិង្ស ឃើញភិក្ខុទាំងពីររូបនោះកំពុងដើរទៅ ក៏គិតថា " ភិក្ខុទាំងពីររូបនេះ មានសាមគ្គីរួបរួមគ្នាយ៉ាងជិតដិតខ្លាំងណាស់ តើអាត្មាអញអាចនឹងបំបែកភិក្ខុទាំងពីររូបនេះ កុំឲ្យមានការរួបរួមគ្នាបានឬទេ ? គិតភ្លាមក៏មកដល់ក្នុងទីនោះ ១ រំពេច ព្រោះទេវតានោះ ជាទេវតាពាល ។ រីឯភិក្ខុទាំងពីររូប កាលដែលកំពុងតែដើរ ភិក្ខុ ១ រូបបាននិយាយទៅនឹងភិក្ខុជាសំឡាញ់ថា " សូមឲ្យរង់ចាំក្នុងទីនេះ ១ រំពេចសិន ខ្ញុំត្រូវការបោយសរីរកិច្ច (បន្ទោបង់) ។ ក្នុងពេលដែលភិក្ខុ ១ អង្គធ្វើសរីរកិច្ច រួចចេញពីចន្លោះគុម្ពឈើមកវិញ ទេវតានោះនិម្មិតធ្វើជាស្រីមនុស្សជំទង់ ១ នាក់ ដៃម្ខាងចាប់ផ្នួងសក់ ដៃម្ខាងចាប់សំពត់ស្លៀក ដើរចេញពីខាងក្រោយខ្នងភិក្ខុនោះ ភិក្ខុនោះឥតបានឃើញរូបស្រីដែលទេវតានិម្មិតនោះទេ ប៉ុន្តែ ភិក្ខុជាសំឡាញ់ដែលឈរចាំនោះ ងាកក្រឡេកមើលទៅឃើញស្រីដែលកំពុងកាន់ចាប់ផ្នួងសក់ និងកំពុងចាប់សំពត់ស្លៀកដើរចេញទៅ ។ រីឯទេវតា កាលបើដឹងថា ភិក្ខុដែលឈររង់ចាំបានឃើញខ្លួនច្បាស់ហើយ ក៏បាត់ភ្លាមក្នុង

ទីនោះទៅ ។ ភិក្ខុជាសំឡាញ់ដែលរង់ចាំ កាលដែលភិក្ខុទៅបន្ទាប់ត្រឡប់មកដល់វិញក៏និយាយថា "ម្នាលអាវុសោ! សីលរបស់លោកបែកធ្លាយហើយ" ។ ភិក្ខុអ្នកបន្ទាប់ឆ្លើយថា "សីលរបស់ខ្ញុំឥតបែកធ្លាយសោះទេ" ។ ភិក្ខុអ្នករង់ចាំ និយាយថា "អម្បាញ់មិញនេះ ខ្ញុំបានឃើញស្រី ១ នាក់ចេញទៅអំពីខាងក្រោយលោកធ្វើអាការយ៉ាងនេះៗ លោកឯងនៅតែនិយាយថាគ្មានទេៗ" ។

ភិក្ខុអ្នកបន្ទាប់ ឮដូច្នោះ ក៏ដល់នូវសភាពជ្រប់ក្នុងខ្លួន ហាន អាការដូចជារន្ទះបាញ់ត្រូវក្បាល ក៏និយាយតទៅទៀតថា "ម្នាលអាវុសោ! លោកកុំធ្វើឲ្យខ្ញុំវិនាសឡើយ អំពើដូចលោកនិយាយនោះគ្មានសោះតែម្តង ។ ភិក្ខុអ្នករង់ចាំនិយាយថា "អំពើនេះ គឺខ្ញុំឃើញ ដោយភ្នែកខ្ញុំខ្លួនឯង ខ្ញុំនឹងជឿសំដីលោក ដូចម្តេចបាន" និយាយរួចក៏ដើរបែកចេញអំពីភិក្ខុជាសំឡាញ់នោះទៅ ហើយទៅអង្គុយនៅក្នុងរោងឧបោសថ និយាយទៀតថា "ខ្ញុំ នឹងមិនធ្វើឧបោសថកម្ម ជាមួយនឹងភិក្ខុទ្រុស្តសីលនេះទេ" ។ ភិក្ខុអ្នកបន្ទាប់បាននិយាយចំពោះភិក្ខុទាំងឡាយថា "សីលរបស់ខ្ញុំឥតសៅហ្មងអ្វីទេ សូម្បីតែមានពណ៌ខ្មៅប៉ុនគ្រាប់ល្ងក៏គ្មានដែរ", ភិក្ខុ

អ្នកនេះចាំ បាននិយាយប្រាប់ភិក្ខុទាំងឡាយថា អំពើនេះ គឺខ្លួនខ្ញុំ ឃើញដោយភ្នែកខ្ញុំខ្លួនឯងតែម្តង គឺច្បាស់ណាស់" ។ រីឯទេវតា លុះឃើញថាភិក្ខុជាសំឡាញ់បែកគ្នាលែងត្រូវគ្នានឹងធ្វើឧបោសថ-កម្មរួមជាមួយនឹងភិក្ខុនោះហើយ ក៏គិតថា "អំពើដែលអញបាន ធ្វើហើយ ជាកំពើមានទម្ងន់" ទើបទេវតានោះទៅស្រែកប្រកាស ឰអាកាសថា "បពិត្រព្រះករុណាទាំងឡាយគ្រប់ព្រះអង្គ, លោក ម្ចាស់របស់ខ្ញុំគ្មានសីលទេ គឺបែកធ្លាយសីលទេ រូបស្រីដែល ចេញពីក្រោយខ្នងលោកម្ចាស់របស់ខ្ញុំនោះ គឺខ្លួនខ្ញុំនិម្មិតធ្វើ ដើម្បី នឹងល្បងមើលទេតើ, សូមព្រះករុណាគ្រប់អង្គធ្វើឧបោសថកម្ម ជាមួយ នឹងលោកម្ចាស់របស់ខ្ញុំនោះចុះ" ។ ភិក្ខុដែលធ្លាប់ជាមិត្រ សំឡាញ់នោះលុះឮពាក្យទេវតាដូច្នោះក៏ជឿ ហើយបានធ្វើឧបោសថ-កម្មក្នុងពេលនោះទៅ ប៉ុន្តែពុំបានចិត្តទន់ភ្លន់ល្អដូចកាលមុនឡើយ ។

ទេវតានោះ ដោយអំណាចកំពើអាក្រក់ ដែលខ្លួនបានធ្វើក្នុង ពេលនោះ ជាអំពើនាំឲ្យភិក្ខុទាំងពីររូបបែកបាក់សាមគ្គី, លុះច្យុត អំពីទេវលោកមក បានទៅកើតនៅក្នុងនរកអវិចី ហើយឆេះក្នុង នរកនោះអស់រយៈកាល ១ ពុទ្ធន្តរ ហើយវិលកើតស្លាប់ចុះឡើង ៗ

លុះដល់មកក្នុងពុទ្ធកាលនេះ បានកើតជាមនុស្សនៅក្នុងក្រុងសាវត្ថី ហើយបានទទួលបព្វជ្ជានិងឧបសម្បទាក្នុងព្រះពុទ្ធសាសនា ។ តាំងពីថ្ងៃដែលលោកនោះបានបួសឡើង មានរូបស្រីម្នាក់ជាប់ប្រកិតតាមពីក្រោយ ដោយអំណាចបាបកម្ម ដែលខ្លួនបានធ្វើក្នុងអតីតកាល កាលដែលខ្លួនកើតជាទេព្តា ។ ដោយហេតុនោះឯង បានជាគេនាំគ្នាហៅភិក្ខុនោះថា "គោណ្ឌធានត្ថេរ" ជាប់តមក ។

គោណ្ឌធានត្ថេរនោះ ឥតឃើញរូបស្រីនោះទេ ប៉ុន្តែមហាជនគេមើលឃើញរូបស្រីនោះ តាមពីក្រោយលោកជានិច្ច ។ គោណ្ឌធានត្ថេរនោះ កាលដែលទើបនឹងបួសឡើងថ្មី ៗ ពុំបានសេចក្តីសុខស្រួលទេ ដោយហេតុត្រូវព្រះសង្ឃឯទៀតពោលទោសចោទប្រកាន់ អំពីមានរូបស្រីតាមពីក្រោយ គេត្រូវការបណ្តេញចេញកុំឲ្យនៅក្នុងវត្តអារាមតទៅទៀត ប៉ុន្តែ នៅក្រោយពេលដែលព្រះមហាក្សត្រទៅពិនិត្យមើលរូបស្រីនោះ ទើបដឹងប្រាកដថា រូបស្រីនោះមិនមែនជារូបស្រីមែនទែនទេ គ្រាន់តែជានិមិត្តរូបដូចជាស្រមោលអន្ទោលតាមប្រាណរបស់លោកប៉ុណ្ណោះ ទើបពាក្យចោទប្រកាន់ផ្សេងៗ ក៏ស្ងប់បាត់ទៅ ។

និទានកថាសង្ខេប ដែលនាំយកមកពោលក្នុងទីនេះ ដើម្បីសូមឲ្យអស់លោកជាបណ្ឌិត និងគ្រហស្ថទាំងឡាយ ទុកជាឧទាហរណ៍សម្រាប់ពិចារណាឲ្យឃើញថា ការបំបាក់បំបែកសាមគ្គីនាំឲ្យមានទោសធ្ងន់ណាស់ គួរតែចៀសវាងឲ្យឆ្ងាយ គួរតែកុំធ្វើឲ្យសោះ ។ សូមពិចារណាឲ្យយល់ច្បាស់ថា ទេវទត្តដែលបំបែកសាមគ្គីនោះ មិនទាំងពេញ ១ ថ្ងៃផង ក៏បានបាបជាទម្ងន់ម៉្លោះទៅហើយ ចំណាន់បើអ្នកណាមួយដែលព្យាយាមបំបែកសាមគ្គីរាប់ខែរាប់ឆ្នាំ តើនឹងបានបាបធ្ងន់ជាងនោះទៀតយ៉ាងណាទៅ ? បាបនេះ សាហាវឃោរឃៅណាស់ គួរតែខ្លាច ពុំគួរហ៊ានប្រថុយធ្វើឡើយ ។

— ចប់ —

**សូមព្រះពុទ្ធសាសនា និងប្រទេសកម្ពុជា**
**មានសាមគ្គីធម៌ !**

**សូមព្រះពុទ្ធសាសនា និងប្រទេសកម្ពុជា**
**ប្រាសចាកសាមគ្គីភេទ !**